ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាខេត្តព្រៃវែង

លេខ ០១៣៧ សជណ/១១

## សេចក្តីជូនដំណឹង

## ស្តីពីអាករលើសេវាលំហែកំសាន្តផ្សេងៗ

- បានឃើញប្រកាសលេខ ៣៤១ ប្រក.សហវ.ពដ ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីអាករពិសេសលើទំនិញ និងសេវាមួយចំនួន
- បានឃើញប្រកាសលេខ ១៥៣ ប្រក.សហវ.ពដ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីអាករពិសេសលើសេវាលំហែកំសាន្តផ្សេងៗ។

អភិបាលនៃគណៈអភិបាលខេត្តសូមជូនដំណឹងថា៖

១- ត្រូវបានចាត់ទុកថាជាសេវាលំហែកំសាន្ត ជាអាទិ៍មាន៖ ការប្រគុំតន្ត្រី ចាក់ភ្លេង សំដែងល្ខោនតុក្កតា ឬកាយវិការ មានលក្ខណៈជាសកម្មភាពអាជីវកម្មនៅក្នុងខារាអូខេ ទីកន្លែងសាធារណៈ ឬកន្លែងណាមួយ។ ម៉ាស្សា ស្តុកឃ័រ ហ្គេមគ្រប់ប្រភេទ។

២- អាករពិសេសលើសេវាលំហែកំសាន្ត ត្រូវប្រមូលតាមអត្រា ១០% លើថ្លៃទំនិញ និងសេវាកត់ត្រាក្នុងវិក្ក័យប័ត្រ ដោយមិនទាន់គិតបញ្ចូលអាករពិសេសខ្លួនឯង និងអាករលើតម្លៃបន្ថែម។

៣- អាករលើសេវាលំហែកំសាន្តផ្សេងៗ ត្រូវបង់ប្រចាំខែយ៉ាងយឺតត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់ នៅស្នាក់ការពន្ធដារ ស្រុក-ក្រុង ដែលអាជីវកម្មដ្ឋានស្ថិតនៅ។

ទទួលបាននូវសេចក្តីជូនដំណឹងនេះ អភិបាលនៃគណៈអភិបាលខេត្តមានជំនឿថា គ្រប់អ្នកជាប់ពន្ធទាំងអស់នឹងបំពេញកាតព្វកិច្ចបង់អាករពិសេសលើសេវាលំហែកំសាន្ត បានទាន់ពេលវេលាកំណត់ជាមិនខានឡើយ។

ព្រៃវែង,ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១១

**អភិបាលនៃគណៈអភិបាលខេត្ត**

អ៊ុង_សាមី

**កន្លែងទទួល៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រុមប្រឹក្សាខេត្តព្រៃវែង
  "គោរពជូនជ្រាប"
- សាលាស្រុក-ក្រុង
- សាខាពន្ធដារខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ